# ក្របខណ្ឌភាពជាដៃគូរបស់ធនាគារពិភពលោកប្រចាំកម្ពុជា សម្រាប់ឆ្នាំ២០២៥-២០២៩
## កំណត់ហេតុសង្ខេបនៃកិច្ចប្រជុំពិគ្រោះយោបល់ជាមួយក្រសួងពាក់ព័ន្ធនៅថ្នាក់ជាតិ
## ថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០២៣
## សណ្ឋាគារ Raffles Le Royal, ភ្នំពេញ

នៅថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០២៣ ការិយាល័យរបស់ធនាគារពិភពលោកប្រចាំនៅកម្ពុជា បានបើកកិច្ចប្រជុំពិគ្រោះយោបល់លើកទី១ ជាមួយក្រសួងពាក់ព័ន្ធថ្នាក់ជាតិ និងដៃគូរដ្ឋាភិបាល ដើម្បីពិភាក្សាប្រមូលគំនិតសម្រាប់រៀបចំឯកសារ ក្របខណ្ឌភាពជាដៃគូប្រចាំប្រទេសកម្ពុជា សម្រាប់ឆ្នាំ២០២៥-២០២៩ ដែលសរសេរកាត់ជាអង់គ្លេសថា CPF ។ កិច្ចប្រជុំនេះមានអ្នកចូលរួម ១៤០នាក់ ដែលជាតំណាងមកពីក្រសួងនានា (សូមមើលឧបសម្ព័ន្ធភ្ជាប់មកជាមួយ)។

## ទិដ្ឋភាពរួម

កិច្ចពិគ្រោះយោបល់បានផ្តើមឡើងជាមួយនឹងប្រសាសន៍ស្វាគមន៍ របស់លោកស្រី Mariam J. Sherman, នាយិកានៃការិយាល័យរបស់ធនាគារពិភពលោកប្រចាំប្រទេសកម្ពុជា, មីយ៉ាន់ម៉ា និងឡាវ និងប្រសាសន៍របស់ឯកឧត្តម រស់ សីលវ៉ា រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

កិច្ចប្រជុំមានការធ្វើបទបង្ហាញជូនអ្នកចូលរួម ស្តីពីវឌ្ឍនភាព, បញ្ហាប្រឈម និងកាលានុវត្តភាពនៅកម្ពុជា ដូចមានលើកឡើងនៅក្នុងការវិភាគជាប្រព័ន្ធរបស់ធនាគារពិភពលោកអំពីស្ថានភាពក្នុងប្រទេស (World Bank's Systematic Country Diagnosis) អមជាមួយសេចក្តីសង្ខេបសំណើសម្រាប់រៀបចំ CPF។ បទបង្ហាញទាំងអស់ត្រូវបានរៀបចំធ្វើឡើង និងបង្ហាញជូនអង្គប្រជុំ ដោយបុគ្គលិករបស់ធនាគារពិភពលោក។ ឯកសារទាំងនេះអាចរកបាននៅក្នុងវេបសាយនេះ Cambodia CPF FY25-29 consultation website ។

បន្ទាប់ពីពិធីបើក អ្នកចូលរួមត្រូវបានចែកជាក្រុមតូចៗ ផ្អែកតាមលទ្ធផលរំពឹងទុកកម្រិតខ្ពស់ចំនួនបី (High Level Outcomes/HLO) នៅក្នុងឯកសារព្រាង CPF ដើម្បីធ្វើការពិភាក្សាលើសំណួរចំនួនបួន។ ខាងក្រោមជាចម្លើយសង្ខេបដែលស្រង់ចេញពីវគ្គពិភាក្សាក្នុងកិច្ចប្រជុំនោះ៖

| **សំណួរទី១៖ តើអ្វីខ្លះដែលជាបញ្ហាបីកំពូលគេ ដែលក្រុមធនាគារពិភពលោកគួរផ្តោតការយកចិត្តទុកដាក់លើ សម្រាប់រយៈពេល ៤ ទៅ ៥ឆ្នាំខាងមុខ?** |
|---|
| **HLO 1 –** មានពីរក្រុមដែលពិភាក្សា HLO1។ អ្នកឆ្លើយក្នុងក្រុមដំបូងគេ បានលើកទឹកចិត្តឱ្យធនាគារពិភពលោកបន្តជួយដល់វិស័យសុខាភិបាល ដោយផ្សារភ្ជាប់ជាមួយយុទ្ធសាស្ត្របញ្ចកោណរបស់រាជរដ្ឋាភិបាល។ មតិលើកឡើងបានសង្កត់ធ្ងន់ទៅលើការបង្កើនគុណភាពនៃការផ្តល់សេវា នៅតាមគ្រឹះស្ថានសុខាភិបាលនៅថ្នាក់ក្រោមជាតិ (មានមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែក), អាហារូបត្ថម្ភសម្រាប់ទ្រទ្រង់សុខភាពល្អ, និងលើសំណើឱ្យផ្តោតការយកចិត្តទុកដាក់លើសេវាអាហារូបត្ថម្ភ តាមរយៈការបង្កើនការយល់ដឹងនិងការផ្តល់សេវាដល់ម្តាយ និង |

កុមារ ជាពិសេសនៅតាមបណ្តាខេត្តដែលការយល់ដឹងនៅមានកម្រិត។ អ្នកឆ្លើយក៏បានជំរុញធនាគារពិភពលោកផងដែរ ឱ្យផ្តោតទៅលើជំងឺមិនឆ្លង ជាពិសេសជំងឺលើសឈាម និងជំងឺទឹកនោមផ្អែម។ ក្រុមនេះក៏បានធ្វើការកត់សម្គាល់ដែរអំពីកិច្ចសម្របសម្រួលអន្តរក្រសួង – មានក្រសួងសុខាភិបាល, អប់រំ, កសិកម្ម និងបរិស្ថាន – សម្រាប់ជំរុញការងារឆ្ពោះទៅរកអភិក្រមសុខាភិបាលតែមួយ (One Health approach) ជាមួយនឹងការលើកឡើងអំពីការផ្ទុះជំងឺផ្តាសាយបក្សី H5N1 នៅក្នុងប្រទេសកាលពីពេលថ្មីៗ និងការដាស់តឿនឱ្យយកចិត្តទុកដាក់លើបញ្ហាសុវត្ថិភាពអាហារ។

លើចំណុចស្តីពីការអប់រំ អ្នកចូលរួមបានលើកឡើងអំពីការចុះឈ្មោះចូលរៀន, គុណភាពរបស់គ្រូបង្រៀន, និងការកសាងសមត្ថភាព ថាវាជាចង្កោមអាទិភាព ទន្ទឹមគ្នាជាមួយនឹងលទ្ធភាពទទួលបានការអប់រំ និងការអប់រំកូនក្មេងផងដែរ។ អ្នកចូលរួមខ្លះ បានធ្វើការកត់សម្គាល់អំពីភាពចាំបាច់ឱ្យមានការគាំទ្របន្ថែមទៀត ដល់មណ្ឌលថែទាំកុមារ និងមត្តេយ្យសាលានៅតាមសហគមន៍។ លើសារៈសំខាន់នៃការកសាងសមត្ថភាព មានយោបល់លើកឡើងថាគេមិនគួរផ្តោតលើបញ្ហាគុណភាពគ្រូតែមួយមុខទេ ប៉ុន្តែត្រូវដោះស្រាយរឿងប្រសិទ្ធផលនៃចំណាយ, លទ្ធកម្ម និងការពង្រឹងស្ថាប័ន ផងដែរ។ ជាងនេះទៀត ពួកគេបានសង្កត់ធ្ងន់លើភាពចាំបាច់ឱ្យមានការបណ្តុះបណ្តាលជំនាញ TVET កាន់តែច្រើនសម្រាប់សិស្សឈប់រៀនពីសាលា, សម្រាប់ការផ្គូផ្គងការងារលើទីផ្សារ និងការតម្រង់ទិសអាជីពសម្រាប់យុវជន។ ការកត់សម្គាល់ត្រូវបានធ្វើឡើងនៅលើសារៈសំខាន់ការពាក់ព័ន្ធជាមួយផ្នែកឯកជនក្នុងការកសាងឱកាសការងារ (តភ្ជាប់ការអភិវឌ្ឍជំនាញជាមួយតម្រូវការជំនាញនៅក្នុងវិស័យឯកជន) និងលើការកំណត់ឱ្យបាននូវវិស័យនានាសម្រាប់ធ្វើការបំប៉នជំនាញឡើងវិញ ឬធ្វើវិក្រឹត្យការជំនាញ បន្ថែមទៀត។ ទូលាយជាងនេះ មានសមាជិកមួយចំនួននៅក្នុងក្រុមនេះ បានលើកឡើងថា វិស័យឯកជនគួរតែចូលពាក់ព័ន្ធនៅក្នុងការផ្តល់សេវា ផងដែរ។

**HLO 2 –** ក្រុមដែលពិភាក្សា HLO2 បានកំណត់ថាជាអាទិភាព នូវភាពចាំបាច់កែលម្អក្របខណ្ឌច្បាប់ជុំវិញការធ្វើពាណិជ្ជកម្ម និងការវិនិយោគ និងការជំរុញភាពប្រកួតប្រជែងតាមរយៈការកែលម្អឱ្យប្រសើរនូវបរិស្ថានសម្រាប់ឡូហ្ស៊ីស្ទិក និងធុរកិច្ច។

មានការលើកឡើងអំពីភាពចាំបាច់ដើម្បីកែលម្អបណ្តាញផ្លូវក្នុងផ្ទៃប្រទេស និងកាត់បន្ថយថ្លៃចំណាយលើឡូហ្ស៊ីស្ទិក។ ពួកគេបានសង្កត់ធ្ងន់លើបណ្តាញផ្លូវជនបទក្នុងផ្ទៃប្រទេស។ បន្ថែមលើនេះ អ្នកចូលរួមបានធ្វើការកត់សម្គាល់លើបណ្តាញតភ្ជាប់ផ្លូវក្នុងតំបន់ ឧទាហរណ៍ជាមួយវៀតណាម ដែលជាប្រទេសសំខាន់មួយសម្រាប់ការនាំចេញកសិផលពីកម្ពុជា។

មានសំណើលើកឡើងសុំឱ្យមានជំនួយបច្ចេកទេស (TA) សម្រាប់កំណត់អត្តសញ្ញាណឧបសគ្គផ្នែកឡូហ្ស៊ីស្ទិក និងការលំបាកផ្នែកស្ថាប័ន អមជាមួយសំណើឱ្យមានការគាំទ្របន្ថែមទៀតដល់សហគ្រាសខ្នាតតូច និងមធ្យម។ លទ្ធភាពទទួលបានទុនហិរញ្ញវត្ថុ ជាពិសេសសម្រាប់ស្ត្រីនៅជនបទ ត្រូវបានចាត់ទុកថាជាបញ្ហាសំខាន់។

**HLO 3 –** ក្រុមដែលពិភាក្សាលើ HLO3 បានផ្តោតទៅលើជំនួយខ្នាតតូច ដោយពួកគេបានលើកឡើងថា ធនាគារពិភពលោកគួរជួយដល់ក្រុមគ្រួសារងាយរងគ្រោះឱ្យពង្រឹងភាពធន់របស់ខ្លួន តាមរយៈការជួយ រួមទាំងការកសាង

សមត្ថភាព ដល់កសិករខ្នាតតូចឱ្យមានបរចិញ្ចឹមជីវិតប្រសើរឡើង។ ក្រុមនេះបានកត់សម្គាល់ផងដែរលើភាពចាំបាច់ឱ្យមានការវិនិយោគក្នុងមូលដ្ឋាន មានដូចជាការវិនិយោគទៅលើហេដ្ឋារចនាសម្ព័ន្ធ, ការវិនិយោគក្នុងមូលដ្ឋានលើបញ្ហាអាកាសធាតុ, ការគ្រប់គ្រងធនធានទឹកប្រកបដោយភាពធន់, បច្ចេកវិទ្យា, ការផ្សព្វផ្សាយកសិកម្ម, និងការពាក់ព័ន្ធរបស់សហគមន៍ក្នុងបញ្ហាព្រៃសហគមន៍។ ចំពោះការគាំទ្រឱ្យមានភាពធន់កាន់តែខ្លាំងជាងមុន អ្នកចូលរួមបានធ្វើការកត់សម្គាល់ដែរ អំពីភាពចាំបាច់នៃការវិនិយោគឯកជន និងការគាំទ្ររបស់ដៃគូ ជាពិសេសពីសំណាក់ក្រុមសង្គមស៊ីវិល។ ជាងនេះទៅទៀត ពួកគេបានសង្កត់ធ្ងន់លើសារៈសំខាន់នៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ, ការពង្រឹងស្ថាប័ន និងការកសាងសមត្ថភាពស្ថាប័ន នៅកម្រិតវិមជ្ឈការ ដើម្បីកាត់បន្ថយភាពក្រីក្រ។

**សំណួរទី២៖ ដោយមើលទៅលើឧត្តមភាពប្រៀបធៀបដែលធនាគារពិភពលោកកំពុងមាន តើនៅក្នុងផ្នែកអ្វីខ្លះនៅកម្ពុជាដែលធនាគារពិភពលោកគួរធ្វើសកម្មភាពតិចជាងមុន?**

**HLO 1 –** អ្នកចូលរួមដែលពិភាក្សាបញ្ហាសុខាភិបាល និងអប់រំ បានលើកឡើងអំពីភាពស្មុគស្មាញនៅក្នុងដំណើរការងាររបស់ធនាគារពិភពលោក ដោយពួកគេនិយាយថាវាមានភាពលំបាកខ្លាំង ហើយទទូចធនាគារពិភពលោកឱ្យសម្រួលវាខ្លះវិញ។ បន្ថែមលើនេះ ពួកគេក៏បានលើកឡើងអំពីកង្វះការបណ្តុះបណ្តាលសម្រាប់ក្រសួងដែរ។

អ្នកចូលរួមមានទស្សនៈដែរថា ការអនុវត្តគម្រោងដែលទទ្រង់ហិរញ្ញវត្ថុដោយធនាគារពិភពលោក អាចសម្រួលបានកាន់តែប្រសើរបើសិនជាជួលកុងស៊ុលតង់ក្នុងស្រុកនៅក្នុងប្រទេស ឱ្យមកធ្វើការ។ ពួកគេបានលើកឡើងថាដំណើរការកិច្ចសន្យាជួលកុងស៊ុលតង់អន្តរជាតិ ត្រូវការពេលវេលាច្រើន ហើយជួនកាលកុងស៊ុលតង់ដែលជាមុខសញ្ញាត្រូវជួលនោះ អត់ទំនេរភ្លាមៗសម្រាប់មកជួយដល់ការអនុវត្តគម្រោងទេ។

អ្នកផ្តល់ចម្លើយផ្សេងទៀត បានបន្ថែមថា គម្រោងរយៈពេលវែងចាំបាច់ត្រូវសម្របខ្លួនទៅទទួលយកបច្ចេកវិទ្យាថ្មីៗមកប្រើ តាមលទ្ធភាពដែលអាចធ្វើបាន។ ពួកគេក៏បានកត់សម្គាល់ផងដែរអំពីភាពចាំបាច់ក្នុងការពង្រឹងការផ្តោតអារម្មណ៍ និងភាពទាន់ពេលវេលានៃការបោះពុម្ពផ្សាយកិច្ចការស្រាវជ្រាវ ហើយលើកមកពិភាក្សាជាមួយរដ្ឋាភិបាល ដើម្បីឱ្យគេឃើញថាកិច្ចការស្រាវជ្រាវនោះមានប្រយោជន៍ពាក់ព័ន្ធជាមួយអាទិភាពរបស់រដ្ឋាភិបាលសម្រាប់ទទួលការគាំទ្រដល់ការយកលទ្ធផលរកឃើញ និងអនុសាសន៍នៅក្នុងការស្រាវជ្រាវនោះ ទៅអនុវត្ត។

**HLO 2 –** អ្នកធ្វើអត្ថាធិប្បាយលើ HLO 2 ក៏បានលើកឡើងដែរអំពីការជួលកុងស៊ុលតង់អន្តរជាតិដែលមានការយល់ដឹងតិចតួចអំពីបរិបទក្នុងស្រុក ថាវាជាបញ្ហាដែលនាំឱ្យមានការយឺតយ៉ាវដល់ការអនុវត្តកម្មវិធីដែលគាំទ្រហិរញ្ញវត្ថុដោយធនាគារពិភពលោក។

**HLO 3 –** ក្រុមពិភាក្សាលើ HLO 3 បានអំពាវនាវឱ្យដៃគូអភិវឌ្ឍន៍ធ្វើការសម្របសម្រួលគ្នាឱ្យបានល្អជាងមុន ដើម្បីកាត់បន្ថយភាពត្រួតស៊ីគ្នានៃកម្មវិធីរបស់ពួកគេ។ សមាជិកនៅក្នុងក្រុមមួយបានស្នើឡើងដែរឱ្យមានការផ្តោតកាន់តែច្រើនទៅលើការដាំដុះដំណាំដែលមានភាពធន់នឹងអាកាសធាតុ។

| |
|---|
| **សំណួរទី៣៖ តើលោកអ្នកយល់ឃើញដូចម្តេចដែរអំពី លទ្ធផលរំពឹងទុកកម្រិតខ្ពស់ (HLO) និង គោលបំណង ដែលបានស្នើឡើងសម្រាប់រៀបចំក្របខណ្ឌ CPF នេះ?** |
| ក្រុមពិភាក្សាទាំងអស់បានសម្តែងការគាំទ្រចំពោះ លទ្ធផលរំពឹងទុកកម្រិតខ្ពស់ (HLO) និង គោលបំណង ដែលបានស្នើឡើង ជាមួយនឹងការកត់សម្គាល់ថា វាបានសម្របខ្លួនតាមយុទ្ធសាស្ត្របញ្ចកោណរបស់រដ្ឋាភិបាល។ ជាង នេះទៅទៀត គោលបំណងដែលផ្តោតទៅលើផ្នែកពាណិជ្ជកម្ម និងបណ្តាញផ្លូវតភ្ជាប់ មានខ្លឹមសារស្រដៀងទៅនឹងអ្វីដែលក្រុមពិភាក្សាបានលើកឡើងក្នុងការជជែកអំពី HLO2 ដែរ។<br><br>**HLO 1 –** HLO 1 និងគោលបំណងពាក់ព័ន្ធ ទទួលបានការគាំទ្រ ដោយសារវាមានការសម្របតាមជិតស្និទ្ធជាមួយយុទ្ធសាស្ត្របញ្ចកោណរបស់រដ្ឋាភិបាល។<br><br>**HLO 2 –** HLO2 ទទួលបានការគាំទ្រ ជាពិសេសគោលបំណងនៅក្នុងនោះដែលផ្តោតលើពាណិជ្ជកម្ម ហើយបញ្ហាស្តីពីបណ្តាញផ្លូវតភ្ជាប់ក៏ទទួលបានការគាំទ្រដែរ។<br><br>**HLO 3 –**HLO 3 ទទួលបានការគាំទ្រ។ មានការគាំទ្រទូលំទូលាយផងដែរចំពោះទិសដៅរបស់ CPF ហើយអ្នកចូលរួមបានផ្តល់ការទទួលស្គាល់ចំពោះការសម្របខ្លួនរបស់ឯកសារក្របខណ្ឌនេះ ទៅតាមអាទិភាពរបស់រដ្ឋាភិបាល។ |
| **សំណួរទី៤៖ តើតាមរបៀបណាខ្លះដែលធនាគារពិភពលោកអាចឆ្លើយតបបានកាន់តែប្រសើរ ទៅនឹងបញ្ហាប្រឈមអន្តរវិស័យពាក់ព័ន្ធជាមួយ៖**<br>- **ឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ**<br>- **អភិបាលកិច្ច និងសមត្ថភាពរបស់ស្ថាប័ន**<br>- **សមភាពយេនឌ័រ និងបរិយាបន្ន** |
| **HLO 1 –** ក្រុមពិភាក្សាផ្តោតលើ HLO1 បានសង្កត់ធ្ងន់លើការបញ្ជ្រាបថែមទៀតនូវបញ្ហាយេនឌ័រ ដើម្បីឆ្លើយតបឱ្យបានកាន់តែប្រសើរទៅលើបញ្ហាសមភាព និងបរិយាបន្ន។ ពួកគេបានលើកឡើងថា ជាមួយការប្រែប្រួលអាកាសធាតុ ចាំបាច់ត្រូវកសាងភាពធន់របស់ស្ត្រីនៅតំបន់ជនបទ និងលើកកម្ពស់ជីវភាពរស់នៅ ឧទាហរណ៍ តាមរយៈការទទួលបានទឹកស្អាត និងដំណាំដែលធន់នឹងអាកាសធាតុ។ ពួកគេក៏បានធ្វើការកត់សម្គាល់ដែរ អំពីឱកាសក្នុងការរៀបចំឱ្យមានកន្លែងធ្វើការ និងសាលារៀនឱ្យកាន់តែមានភាពបៃតងជាងមុន។ លើផ្នែកអភិបាលកិច្ច ការសង្កត់ធ្ងន់ត្រូវបានធ្វើឡើងលើបញ្ហាសមត្ថភាពស្ថាប័ន, ការបញ្ជាក់ឱ្យបានច្បាស់អំពីតួនាទី និងការទទួលខុសត្រូវក្នុងជួររដ្ឋាភិបាល និងការរៀបចំថវិកាប្រកបដោយប្រសិទ្ធភាព។<br><br>**HLO 2 –** ក្រុមដែលពិភាក្សា HLO2 បានស្នើឱ្យមានការផ្តោតកាន់តែច្រើនទៅលើការស្រាវជ្រាវជុំវិញបញ្ហាសេដ្ឋកិច្ចចក្រានៅកម្ពុជា ដើម្បីជួយបំពេញដល់លទ្ធផលរំពឹងទុកផ្នែកអាកាសធាតុ។ ពួកគាត់បានស្នើឱ្យមានការគាំទ្រថែមទៀតដល់ការកែទម្រង់រដ្ឋាភិបាល, កម្មវិធីភាពជាអ្នកដឹកនាំដើម្បីបង្កើតអ្នកកសាងសម្រាប់អនាគត និងបង្កើនការផ្តោតទៅលើការកសាងសមត្ថភាពសម្រាប់ស្ត្រី ដើម្បីកែលម្អអភិបាលកិច្ច និងគណនេយ្យភាពឱ្យកាន់តែប្រសើរឡើង។ |

**HLO 3-** អ្នកពិភាក្សាតាមក្រុមដែលផ្តោតលើ HLO3 បានធ្វើអត្ថាធិប្បាយលើសារៈសំខាន់នៃការបង្កើនកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ, ការគាំទ្របន្ថែមផ្នែកយេនឌ័រនៅក្នុងការងារអភិបាលកិច្ច ដើម្បីអនុវត្តការរៀបចំថវិកាដែលឆ្លើយតបយេនឌ័រ។ ពួកគាត់ក៏បានធ្វើការកត់សម្គាល់ដែរ អំពីតម្រូវការឱ្យមានការកសាងសមត្ថភាពស្ថាប័នបន្ថែមទៀត និងការចូលរួមពីវិស័យឯកជន។ ទាក់ទងគម្រោងដែលទ្រទ្រង់ហិរញ្ញវត្ថុដោយធនាគារពិភពលោក ពួកគាត់បានលើកឡើងម្តងហើយម្តងទៀត អំពីការលើកកម្ពស់ឱ្យមានការយល់ដឹងកាន់តែច្រើននៅក្នុងចំណោមដៃគូអនុវត្ត អំពីភាពជាម្ចាស់ និងគណនេយ្យភាពក្នុងកម្រិតមូលដ្ឋាន ជាពិសេសសម្រាប់គម្រោងខ្នាតតូច។ សមាជិកខ្លះក្នុងក្រុមក៏បានលើកឡើងដែរអំពីសារៈសំខាន់នៃការកែសម្រួលដំណើរការការងារ ឱ្យមានភាពសាមញ្ញជាងមុន និងបង្កើនការសម្របសម្រួលនៃគ្នា ក្នុងចំណោមដៃគូអភិវឌ្ឍន៍។

## ឧបសម្ព័ន្ធ

| **ចំនួនអ្នកចូលរួម** | **វត្តមានរបស់តំណាងតាមក្រសួង** |
|---|---|
| ១៤០នាក់ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>ក្រសួងមហាផ្ទៃ<br>ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>ក្រសួងពាណិជ្ជកម្ម<br>ក្រសួងអប់រំ យុវជន និងកីឡា<br>ក្រសួងបរិស្ថាន<br>ក្រសួងសុខាភិបាល<br>ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>ក្រសួងយុត្តិធម៌<br>ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់<br>ក្រសួងរ៉ែ និងថាមពល<br>ក្រសួងផែនការ<br>ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍<br>ក្រសួងសាធារណការ និងដឹកជញ្ជូន<br>ក្រសួងអភិវឌ្ឍន៍ជនបទ |

| | |
|---|---|
| | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>ក្រសួងទេសចរណ៍<br>ក្រសួងធនធានទឹក និងឧតុនិយម<br>ក្រសួងមុខងារសាធារណៈ<br>ក្រសួងកិច្ចការនារី<br>ក្រសួងអធិការកិច្ច<br>ទីស្តីការគណៈរដ្ឋមន្ត្រី<br>អាជ្ញាធរសេវាកម្មហិរញ្ញវត្ថុមិនមែនធនាគារ<br>ធនាគារជាតិនៃកម្ពុជា<br>គណៈកម្មាធិការជាតិសម្រាប់លេខាធិការដ្ឋានអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ<br>ក្រុមប្រឹក្សាកសិកម្ម និងអភិវឌ្ឍន៍ជនបទ<br>ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>អាជ្ញាធរសវនកម្មជាតិនៃកម្ពុជា<br>អាជ្ញាធរអគ្គិសនីកម្ពុជា<br>គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ |